អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ការប្រកាសសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណុំរឿង កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" នៅថ្ងៃសុក្រ ទី០៣ ខែកុម្ភៈ ឆ្នាំ២០១២

សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ទាក់ទិននឹងជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" នឹងត្រូវប្រកាសនៅ**ថ្ងៃសុក្រ ទី០៣ ខែកុម្ភៈ ឆ្នាំ២០១២** នៅវេលាម៉ោង ១០ ព្រឹក (ម៉ោងក្នុងស្រុក) នៅក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទរូបនេះពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ អង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោសដាក់ពន្ធនាគារ **ឌុច** ចំនួន ៣៥ ឆ្នាំ និងបានផ្តល់សំណងពីរប្រភេទដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ជនជាប់ចោទ សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និង ក្រុម ៣ បានប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរត្រូវបានបញ្ចប់ត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ហើយសវនាការលើបណ្តឹងសាទុក្ខត្រូវបានធ្វើឡើងពីថ្ងៃទី ២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកឯកសារភ័ស្តុតាងសរុបចំនួន ២៦ បន្ថែមទៀតពីសំណាក់ជនជាប់ចោទ និងក្រុមដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។ មានសាធារណជនចំនួនជាង ២.៩០០ នាក់បានតាមដានកិច្ចដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខនេះនៅក្នុងបន្ទប់សវនាការ។ ព័ត៌មានបន្ថែមទាក់ទងនឹងសវនាការនឹងជូនដំណឹងនៅពេលក្រោយ៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ 0២៣
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh